00340473

E65/7

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងលេខ : ០០១/១៨-០៧-២០០៧-អ វ តក/ អជសដ

ដាក់នៅចំពោះមុខ : អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទឯកសារ : ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩

ភាគីដាក់ : សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមទី៣)

ភាសាដើម : បារាំង (បកប្រែជាភាសាខ្មែរ)

ប្រភេទឯកសារ : សាធារណៈ

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de réception): 11 / JUN / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Ly

---

## សារណាឆ្លើយតបរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣) ចំពោះសំណើរបស់ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម១)ទាក់ទងនឹងការផ្សព្វផ្សាយ នៃរបាយការណ៍របស់ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង (BSCI)

---

**ភាគីដាក់**

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
លោក គីម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
អ្នកស្រី Martine JACQUIN
លោក Philippe CANONNE
អ្នកស្រី Annie DELAHAIE
អ្នកស្រី. Elisabeth RABESANDRATANA

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
លោក គង់ ពិសី
លោក ហុង គឹមសួន
លោក យុង ផានិត
អ្នកស្រី ទី ស្រីនណា
អ្នកស្រី Silke STUDZINSKY
លោក Pierre Olivier Sur
លោក Karim KHAN
លោក Alain WERNER
កញ្ញា Brianne McGONIGLE

**នៅចំពោះមុខ**

**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មូណី

**ជនជាប់ចោទ**
កាំងហ្គេច អ៊ាវ ហៅ ឌុច

**សហមេធាវីការពារ**
លោក ការ សាវុធ
លោក François Roux

**ការិយាល័យសហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 16 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Ly

## I. រំលឹកអំពីនីតិវិធី

1. នៅថ្ងៃទី ១១ ខែមិនា ឆ្នាំ២០០៩ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី (ក្រុម១)បានដាក់ទៅអង្គជំនុំជម្រះសាលាដំបូងនូវសំណើមួយដែលស្នើសុំឱ្យតុលាការសម្រួលដល់ការចេញផ្សាយរបាយការណ៍នៃសេវាកម្មផ្ទៃក្នុងរបស់អង្គការសហប្រជាជាតិ ជូនដល់ភាគីនានា[1]។

2. នៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឱ្យភាគីដាក់ការសង្កេតរបស់ខ្លួនក្នុងរយៈពេល១០ថ្ងៃបន្ទាប់ពីការជូនដំណឹងនៃសំណើរបស់សហមេធាវីក្រុម១ រួចមក[2]។

3. នៅថ្ងៃទី ២ មិថុនា ឆ្នាំ២០០៩ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី (ក្រុម៣) ត្រូវបានជូនដំណឹងចំពោះការស្នើសុំដែលបកប្រែជាភាសាបារាំងរបស់ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី (ក្រុម១)។

4. ឆ្លើយតបទៅនឹងបញ្ហាដែលលើកឡើងដោយតុលាការចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០០៩ និងសារណាដែលបានដាក់ដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ កាលពីថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៩ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣ សូមដាក់ជូននូវការសង្កេតដូចខាងក្រោម៖

## II. ការសង្កេត

5. ទោះបីជាយ៉ាងណាក៏ដោយ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣ គ្មានមន្ទិលចំពោះបញ្ហាពុករលួយទៅលើដំណើរការប្រព្រឹត្តទៅបច្ចុប្បន្ននៃសវនាការអង្គសេចក្ដីនោះទេ ដែលថាបញ្ហានេះអាច

[1] រឿងក្ដី កាំងហ្គេកអៀវ ហៅ ឌុច សំណុំរឿងលេខ 001/18-07-2007-អវតក/អជសង សំណើរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ដែលស្នើសុំទៅអង្គសវនាការសម្រួលដល់ការចេញផ្សាយរបាយការណ៍នៃការិយាល័យត្រួតពិនិត្យសេវាកម្មផ្ទៃក្នុងរបស់អង្គការសហប្រជាជាតិ ឯកសារលេខ E65,ERN 00335530-0033553038 (fr)

[2] រឿងក្ដី កាំងហ្គេកអៀវ ហៅ ឌុច សំណុំរឿងលេខ 001/18-07-2007-អវតក/អជសង ការណែនាំដែលកំណត់ពីការអនុញ្ញាតឱ្យភាគីដាក់ការសង្កេតជាលាយលក្ខណ៍អក្សររបស់ខ្លួនទាក់ទងនឹងការស្នើសុំរបស់សហមេធាវីក្រុម១ដែលស្នើដក់សាលាដំបូងសម្រួលដល់ការបញ្ចេញការសម្ងាត់នៃរបាយការណ៍របស់ BSCI នៃអង្គការសហប្រជាជាតិ ជូនដល់ភាគីនានា ឯកសារលេខ E65 ERN 00328883-00328884(fr)

ក្លាយជាចំណែកចូលរួមដោយមានប្រសិទ្ធិភាពទៅលើការវិវត្តរបស់អង្គសវនាការនានាចាប់តាំងពីការបើកសវនាការអង្គសេចក្តីនោះដែរ។

6. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ យល់ឃើញថាគ្រប់ភាគីផ្សេងទៀតនៃដំណើរការនីតិវិធីរួមទាំង ដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទ ឬការិយាល័យសហព្រះរាជអាជ្ញា មិនអាចនៅស្ងៀមយូរទៀតឡើយ ចំពោះអត្ថន័យនៃភាពខុសគ្នាទាំងឡាយនៃរបាយការណ៍ដែលសរសេរដោយការិយាល័យត្រួតពិនិត្យផ្ទៃក្នុងអង្គការសហប្រជាជាតិ ។ ដូច្នេះការបញ្ចេញផ្សព្វផ្សាយជាសាធារណៈនៃរបាយការណ៍ពុករលួយនេះត្រូវតែធ្វើឡើងនៅពេលក្រោយ។

7. ក្នុងន័យនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ស្នើសុំឱ្យមានការផ្តល់របាយការណ៍ឯកសារនេះនៅក្នុងសវនាការអសាធារណៈ ប្រយោជន៍ដើម្បីឱ្យភាគីនីមួយៗនៅចំពោះដំណើរការនីតិវិធីបច្ចុប្បន្នអាចធ្វើការលើកឡើងបាន ហើយ រាល់ការរិះគន់ចំពោះដំណើរការរបស់តុលាការក្នុងអំឡុងពេលនៃការចោទប្រកាន់ទាក់ទងនឹងគោលការណ៍នៃរឿងក្តីប្រកបដោយសមធម៌នោះអាចនឹងក្លាយជាកម្មវត្ថុនៃការដេញដោលដោយផ្ទាល់មាត់។

8. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ស្នើសុំឱ្យតុលាការរក្សាសិទ្ធិក្នុងការប្រកាសជាសាធារណៈ ឬ បើមិនដូច្នោះទេប្រកាសនៅក្នុងការពិភាក្សាលើកក្រោយ។

## **ហេតុដូច្នេះ**

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ចូលរួមគាំទ្រចំពោះការស្នើសុំរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៩។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ស្នើសុំឱ្យធ្វើការផ្សព្វផ្សាយរបាយការណ៍របស់ការិយាល័យត្រួតពិនិត្យផ្ទៃក្នុងអង្គការសហប្រជាជាតិ ក្នុងក្របខណ្ឌនៃការដេញដោលក្នុងសវនាការជាអសាធារណៈ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៩

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣**

**មេធាវី គីម ម៉េងឃី** **មេធាវី ម៉ុច សុវណ្ណារី**

**មេធាវី Annie DELAHAIE** **មេធាវី Martine JACQUIN**

**មេធាវី Philippe CANONNE** **មេធាវី Elisabeth RABESANDRATANA**